ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.ធ៧-០២១-១៣២ ឈ.ស.ណ

ថ្ងៃ អង្គារ ១២កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២១

**ជម្រាបមក**
**លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា**
**គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** ការពង្រឹងការអនុវត្តវិធានការដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងបរិបទនៃព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ។

តតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ឲ្យបានជ្រាបថា ដោយពិនិត្យឃើញសភាពការណ៍វិវត្តថ្មីៗពាក់ព័ន្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងបរិបទនៃព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ និងដើម្បីធានាការផ្តល់សេវាហិរញ្ញវត្ថុជូនអតិថិជនប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ធនាគារជាតិនៃកម្ពុជាសូមក្រើនរំលឹកដល់គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបន្តអនុវត្តវិធានការសុខាភិបាលឲ្យបានម៉ឺងម៉ាត់ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺនេះដូចខាងក្រោម៖

១- បន្តអនុវត្តវិធានការការពារកូវីដ-១៩ "**៣ ការពារ និង ៣ កុំ**" ដូចបានភ្ជាប់ជូនជាមួយ

២- បន្តអនុវត្តឲ្យបានម៉ឺងម៉ាត់ និងតឹងរ៉ឹងតាមវិធានការនានារបស់ក្រសួងសុខាភិបាល ក្នុងការការពារការចម្លងវីរុសកូវីដ-១៩ និង

៣- តម្រូវឲ្យបុគ្គលិកទាំងអស់បន្ត ពាក់ម៉ាស់ និងរបាំងសុវត្ថិភាពការពារមុខ (Safety Face Shield) ជាប់ជាប្រចាំ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកាទាំងអស់ ចូលរួមសហការអនុវត្តឲ្យបានម៉ឺងម៉ាត់និងមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ។

**ជ.ប. ទេសាភិបាល**
**អគ្គនាយកត្រួតពិនិត្យ**

**រ័ត្ន សុវណ្ណនរះ**

## សម្តេចតេជោ ហ៊ុន សែន : វិធានការ ការពារ Covid-19

# ៣ ការពារ និង ៣ កុំ

## ❖ ៣ ការពារ

*១- ពាក់ម៉ាស់*

*២- លាងដៃ*

*៣- គម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល* (ចាប់ពី១ម៉ែត្រកន្លះឡើងទៅឱ្យបានគ្រប់គ្នា នៅគ្រប់ទីកន្លែង និងអនុវត្តឱ្យបានគ្រប់គ្នា) ។

**បញ្ជាក់** : ចំណុច ៣ ការពារ នេះសំខាន់ខ្លាំងណាស់ ដូច្នេះទើបអាចយកឈ្នះលើជំងឺCoivd-19 បានដោយជោគជ័យ។

## ❖ ៣ កុំ

*១- កុំចូលទៅកន្លែងបិទជិត គ្មានខ្យល់ចេញចូល និង ប្រើម៉ាស៊ីនត្រជាក់ច្រើនពេក រកកន្លែងមានខ្យល់ចេញចូល*

*២- កុំទៅកន្លែងមនុស្សច្រើនកុះករ*

*៣- កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា កុំឱបគ្នាជាដើម*